ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមករា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមករា ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសសម្រេចបានចំនួន ៥៧៤ ៥៣៣ហ.ត ស្មើនឹង១២៥,០១% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមករា ឆ្នាំ២០២០នេះ គឺ បានរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងសម្បទានដីសេដ្ឋកិច្ច និងកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែមករា ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៩-២០២០

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៥៧៩ ៦០៦ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៦៥ហ.ត និងដោយគ្រឿងយន្តមានចំនួន ៥៧៥ ៣៤១ហ.ត តិចជាងឆ្នាំមុនចំនួន ៣៣ ៧៤៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៧៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩៧ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៥៧៤ ៥៣៣ហ.ត ស្មើនឹង១២៥,០១% នៃផែនការចំនួន ៤៥៩ ៥៩៤ហ.ត តិចជាង ឆ្នាំមុនចំនួន ២ ៣៧៥ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន ១៧៩ ៤៩៩ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧៧៦ ៤១៨តោន។ ទិន្នផលគិតជាមធ្យម ៤,៣២៥តោន/ហ.ត។

#### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៩-២០២០

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៤ ៥០៧ហ.ត ស្មើនឹង១០៦,៤៩% នៃផែនការចំនួន ៣២ ៤០៣ហ.ត លើសឆ្នាំមុនចំនួន ២ ៤៣៦ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧១ ៣៥៧ហ.ត ស្មើនឹង៦៧,៤០% នៃផែនការចំនួន ១០៥ ៨៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ៤ ៩៦៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## ១.៤ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៥០ ៤៥០តោន មានការថយចុះចំនួន ៩ ១៧៥តោន (-១៥,៣%) តិចជាងបរិមាណនាំចេញក្នុងខែមករា ឆ្នាំ២០១៩ មានចំនួន ៥៩ ៦២៥តោន និងបាននាំចេញទៅកាន់ទិសដៅចំនួន ៤០ប្រទេស ក្នុងនោះ ប្រទេសចិនលំដាប់ទី១ (១៥ ០០៧តោន) ប្រទេសហ្កាបុងលំដាប់ទី២ (៦ ១១៨តោន) ប្រទេសបារាំងលំដាប់ទី៣ (៥ ៦១៧តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (៤ ៤០០តោន) ប្រទេសអង់គ្លេសលំដាប់ទី៥ (៣ ០៥៥តោន) ប្រទេសរ៉ែកលំដាប់ទី៦ (២ ១៨៩តោន) ប្រទេសណេដឺឡែនលំដាប់ទី៧ (២ ១២៧តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៨ (២ ០៧១តោន) ប្រទេសអាល្លឺម៉ង់លំដាប់ទី៩ (១ ៦០៥តោន) និងប្រទេសប្រ៊ុយណេលំដាប់ទី១០ (១ ០៥០តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៤៣ក្រុមហ៊ុន។

# ២ ផ្នែកកៅស៊ូ

## ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្ត ប្រចាំខែ (តោន) | បញ្ចេញលក់ ប្រចាំខែ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៣៥ | - |
| **សរុប I** | | **៦៧០** | **៨០១** | **៣៥** | **-** |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុកគិ្តនិកា អ៊ីនវេសមេនគ្រុប | ១១ ៩៧១ | ១៥ ២៣៣ | ១ ៥៩៥ | ៩៣៧ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ១៦១ | ២ ៣៩៥ | ១៥៧ | - |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៦ ១០៣ | ៨ ៤៧៨ | ៤៣៤ | ២៨២ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៣០៦ | ២ ៧២៤ | ៣២ | - |
| ៥ | ក្រុមហ៊ុនស៊ីហ្វរីសសស៍លីមីធីត (ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៣៧៦ | ៤៣២ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេងអ៊ីនធើណេស៊ិនណល | ៣ ៩០៨ | ៤ ១៨៦ | ៣៨០ | ៥២៥ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣១២ | ៤ ៦៩៤ | ១១០ | ២៣០ |
| ៨ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៩១៨ | ៣ ០៣៧ | ៨៣ | ១២៩ |
| ៩ | ក្រុមហ៊ុនក្រេក(ខេមបូឌា)ខូអិលធីឌី | ៤ ៦៣៩ | ៤ ៧៩៨ | ៥៩៩ | ២១០ |
| **សរុបII** | | **៣៧ ១៧៧** | **៤៩ ៩៥១** | **៣ ៧៦៦** | **២ ៧៤៥** |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧៩ ៣៦១ | ១៩៤ ០៨៨ | ១០ ៦០០ | ១០ ២០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១៣៣ ២៦៩ | ១៦១ ១០៣ | ១៤ ៨០០ | ១៤ ៥០០ |
| **សរុប III** | | **២១២ ៦៣០** | **៣៥៥ ១៩១** | **២៥ ៤០០** | **២៤ ៧០០** |
| **សរុប I + II + III** | | **២៥០ ៤៧៧** | **៤០៥ ៩៤៣** | **២៩ ២០១** | **២៧ ៤៤៥** |

គួរកត់សម្គាល់ថាជ័រកៅស៊ូមានតម្លៃជាមធ្យម ១ ៤៣៣ដុល្លារ/តោន កើនឡើងចំនួន ២០៧ដុល្លារ/តោន (+១៧%) បើធៀបនឹងខែមុន។

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានរៀបចំទីតាំងស្រង់ទិន្នន័យជំងឺ *Oidium* នៅឡូតិ៍ IRAA01 ដល់ IRAA10
- បានអង្កេតការជ្រុះស្លឹក និងចេញផ្កានៅច្បារបង្កាត់ពូជ
- បានថែទាំកូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ SET02 និង SSCT02
- បានស្រង់ទិន្នន័យទឹកជ័រលើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ (d3 d4) ចំនួន ៩ចម្ការពិសោធន៍ ប្រព័ន្ធចង្វាក់ចៀរបង្វិល (d3 d4 d5 d6) ចំនួន ២ចម្ការពិសោធន៍ និងចម្ការពិសោធន៍ថ្មីសាកល្បងការចៀរជ័រដោយប្រព័ន្ធម៉ាស៊ីន Tapping Machine នៅក្នុងមួយចម្ការពិសោធន៍

- បានថែទាំថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០១៩-២០២០
- បានថែទាំកូនកៅស៊ូ Root Trainer ដោយកូនកៅស៊ូតូចចំនួន ៣ក្លូន GT1 IRCA230 និង RRIM600
- បានត្រួតពិនិត្យការស្រោចស្រពកៅស៊ូនៅចម្ការពិសោធន៍នៅឡូតិ៍ ៤២DNW
- បានវាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារបំពាក់ដើម
- បានចុះផ្សព្វផ្សាយសារាចរណែនាំស្ដីពីការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូកម្ពុជាដល់បណ្ដាក្រុមហ៊ុន និងរោងចក្រកែច្នៃកៅស៊ូនៅក្នុងស្រុកចំនួន ៤ខេត្ត គឺខេត្តក្រចេះ មណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង
- បានថែទាំកូនកៅស៊ូគ្រប់ចម្ការពិសោធន៍ ថែទាំថ្នាលបណ្ដុះកូនឆ្នាំ២០១៩-២០២០ និងថែទាំច្បារពូជកៅស៊ូ
- បានត្រួតពិនិត្យការប្រមូលទិន្នន័យគ្រប់ឡូតិ៍ពិសោធន៍នៅក្រៅស្ថានីយ
- បានដាំក្លូនកៅស៊ូមកពីក្រុមហ៊ុន SOCFIN-KCD និង CATAS នៅក្នុងច្បារពូជ
- បានវាស់ទំហំដើមតាមដានការលូតលាស់គ្រប់ចម្ការពិសោធន៍។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានចុះសិក្សា និងប្រមូលទិន្នន័យបឋមអំពីខ្សែច្រវាក់តម្លៃផលិតផលម្រេចនៅខេត្តត្បូងឃ្មុំ
- បានចុះសិក្សាស្វែងយល់ស្ថានភាពទូទៅនៃខ្សែច្រវាក់តម្លៃស្វាយចន្ទីនៅខេត្តកំពង់ធំ
- បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងារអង្កេតស្រាវជ្រាវកន្លងមក និងទិសដៅបន្តរវាងនាយកដ្ឋានកសិ-ឧស្សាហកម្ម ជាមួយ ODA ជប៉ុន
- បានចុះប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងគោលការណ៍អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅខេត្តកំពង់ស្ពឺ
- បានរៀបចំវេទិកាប្រជុំចរចាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងភាគីអ្នកផលិត និងភាគីអ្នកទិញនៅខេត្តតាកែវ
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រថ្មីៗនៃការវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតផលកសិកម្មនៅខេត្តស្ទឹងត្រែង
- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពត
- បានចុះបណ្ដុះបណ្ដាលកសិករស្ដីពីការលើកកម្ពស់ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃផលិតកម្មកសិកម្មនៅខេត្តកំពង់ធំ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០១៩ ចំនួន ១០ផ្ទាំង សម្រាប់ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០
- បានផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ១៨គ្រឿង និងយានយន្តចំនួន ៣៣គ្រឿង ជូនក្រុមហ៊ុនស៊ីវហ្គេក អ៊ិនវេសមេន នៅខេត្តស្ទឹងត្រែង
- បានផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនអនុផលព្រៃឈើជូនដល់អ្នកស្នើសុំចំនួន ២នាក់ មានជ័រទឹកចំនួន ១២០ តោន។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- បានសហការជាមួយអង្គការ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៦គ្រឿង នៅតំបន់ភាគខាងត្បូង និងខាងកើតនៃឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ (គិរីរម្យ) ក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺថតជាប់ដំរីឈ្មោលចំនួន ១ក្បាល ស្វាត្រោសចំនួន ១ក្បាល និងជ្រូកព្រៃចំនួន ៤ក្បាល
- បានផ្ដល់លិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃក្នុងស្រុកចំនួន ១ ០០០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ១ ០៣០ក្បាល
- បានផ្ដល់លិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៤ច្បាប់ ក្នុងនោះ ១០ច្បាប់សម្រាប់ថែរក្សាសត្វក្រចៀកកាំ និង៤ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀត។

### ៤.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- កសិដ្ឋានចំនួន ៦កន្លែងបានថែរក្សា និងបង្កាត់ពូជស្វាក្ដាមសរុបចំនួន ៥៤ ១០០ក្បាល ក្នុងនោះ កូនកើតក្នុងខែចំនួន ២ ៧៣៧ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ២ ០៣១ក្បាល (បក្សីចំនួន ៥៥ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៦២៧ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៣ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៨២ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមបាន ១ ៣៤០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១១,៧៦ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៤.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើទំហំ ១ ២៤២,៦៨២ហ.ត ក្នុងនោះចម្ការពូជឈើ ៩៩ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៥៤ហ.ត ចម្ការឈើដាំទំហំ ១ ០០៤ហ.ត និងចម្ការរុក្ខទិវា ០៩ កក្កដា សរុបទំហំ ៨៥,៦៨២ហ.ត ក្នុងខេត្តកំពតកណ្តាល តាកែវ សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ចុះពិនិត្យទីតាំងសម្រាប់រៀបចំពិធីរុក្ខទិវាថ្នាក់ជាតិនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសំបួរមាសស្ថិតក្នុងភូមិសំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកក្នុងឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ ប្រវែង ៨ ០០០ម៉ែត្រ នៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ។

### ៤.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៩៥ករណី ដោយពិន័យអន្តរការណ៍ចំនួន ២២ករណី និងបញ្ជូនទៅតុលាការចំនួន ៧៣ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងសរុបចំនួន ២៤ម៣ ឈើអារចំនួន ៩៧ម៣ ផ្ទៃដីព្រៃឈើដែលកាប់រានទំហំ ៩៥ហ.ត និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

### ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ប្រកចេញចូលតែមួយ) ចំនួន ១កន្លែង
- បានពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើដាំចំនួន ១ក្រុមហ៊ុន
- បាននាំចេញផលិតផលរានទេវតា និងជ័រទឹកទៅក្រៅប្រទេសមានបរិមាណចំនួន២៦ម៣ និងជ័រទឹកចំនួន៤០តោន ដោយក្រុមហ៊ុនចំនួន២ និងនាំចូលឈើកែច្នៃជ្រុងមានបរិមាណចំនួន៨០ម៣ ដោយក្រុមហ៊ុនចំនួន១
- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១ មានគ្រឿងសង្ហារិមកែច្នៃពីឫស្សីចំនួន១៦តោន។

### ៤.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ១ ១៥៣ ៦៥១ ៨៤២ រៀល និង ១៤៦ ០១០,៤៩ដុល្លារ។

## ៥ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៥.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៥.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** រាជធានី-ខេត្តចំនួន ២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២១ ៧៦៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែង

ចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តធ្វើការឃាត់ចាប់ចំនួន ២ករណី។

- **ការងារផ្សព្វផ្សាយបច្ចេកទេស៖ចូលរួមចុះពិនិត្យទីតាំងសម្រាប់រៀបចំទស្សនកិច្ចពិព័រណ៍ និងព័ត៌មាននៅខេត្តសៀមរាប។**

- **ការងារនីតិកម្មនិងវិវាទ**

- រៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើមឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ នឹងដាក់ប្រជុំនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

- ចូលរួមពិធីសម្បថដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអធិការកិច្ច ក្នុងវិស័យសុខភាពសត្វនិងផលិតកម្មសត្វនៅសាលាដំបូងរាជធានីភ្នំពេញ ពិនិត្យនិងផ្តល់យោបល់ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វលើករណីវិវាទរវាងក្រុមហ៊ុន ច័ន្ទ ឬទ្ធី ត្រេឌីង និងក្រុមហ៊ុន ស៊ីជេជេលជីដាងហ្វីដ (ខេមបូឌា)។

### ៥.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ២៤៤វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ១៤៣ក្បាល។

## ៦ ផែ្នកជលផល

### ៦.១ អាជីវកម្មនេសាទ

៦.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តចំនួន ១ ៣៥០តោន ស្មើនឹង១១,២៥% នៃផែនការ១២ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ ថយចុះចំនួន ៩៥០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តចំនួន ២០ ៦០០តោន ស្មើនឹង៥,៩៧% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ ថយចុះចំនួន ២ ៩០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៦ ៥២០តោន ស្មើនឹង៤.៥០% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ ថយចុះចំនួន ១ ០១០តោន។

៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៧ ៦៨០តោន ស្មើនឹង៦,៩៨% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ១៣០តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ១៥ ៨១១តោន ស្មើនឹង៤,៣៩% នៃផែនការ ៣៦០ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ២ ៦៣៥តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៩ ៦០០ក្បាល ស្មើនឹង៣,២០% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ៥០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥ ០០០ ០០០កូន ស្មើនឹង៦,២៥% នៃផែនការ ២៤០ ០០០ ០០០កូន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៥០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៩៨០តោន ស្មើនឹង៧,២៩% នៃផែនការ៨២ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ៣០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨៩០តោន ស្មើនឹង៩,៨៩% នៃផែនការ ៩ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ១០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣ ៤០០ ០០០លីត្រ ស្មើនឹង៦,១៨% នៃផែនការ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ១០០ ០០០លីត្រ។

### ៦.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៩៩ករណី ប្រៀបធៀបខែមករា ឆ្នាំ២០១៩ ថយចុះចំនួន ៣៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៨៨ករណី និងសមុទ្រចំនួន ១១ករណី។

### ៦.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ១ ០៥០តោន ស្មើនឹង៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ២០តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ២៣០តោន ស្មើនឹង៤,៦០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ១០តោន។

### ៦.៦ ការប្រមូលថវិកា

ចំណូលពីសេវាផ្សេងៗក្នុងវិស័យជលផលបានចំនួន ១៣ ១០៦ ០០០រៀល ស្មើនឹង០,៤៤% នៃផែនការ ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបខែមករា ឆ្នាំ២០១៩ កើនឡើងចំនួន ៦ ៥៦៨ ០០០រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមសិក្ខាសាលាស្តីពីការចាប់ផ្តើមគម្រោង ខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន (CFAVC)

- បានចូលរួមសិក្ខាសាលាចាប់ផ្តើមការដាក់បញ្ចូលមុខវិជ្ជាការគ្រប់គ្រងដីប្រកបដោយចីរភាពសម្រាប់ការអភិវឌ្ឍទៅក្នុងកម្មវិធីសិក្សាសម្រាប់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានទទួលជួបភ្ញៀវមកពីសាកលវិទ្យាល័យកូឡំប៊ីសហរដ្ឋអាមេរិចដើម្បីចុះមកថតទិដ្ឋភាព និងសកម្មភាពជាក់ស្តែងនៅលើវាលស្រែពិសោធន៍ ព្រមទាំងជួបសម្ភាសន៍ផ្ទាល់ជាមួយថ្នាក់ដឹកនាំវិទ្យាស្ថានអំពីការអភិវឌ្ឍស្រូវនៅកម្ពុជា

- បានចុះបើកវគ្គបណ្តុះបណ្តាលកសិករ និងត្រួតពិនិត្យពិសោធន៍ដែលមានអ្នកចូលរួមចំនួន ៦០នាក់ នៅខេត្តតាកែវ ព្រៃវែង បាត់ដំបង និងខេត្តព្រះវិហារ

- បានចុះតាមដានការងារពិសោធន៍ដំឡូងមីនៅខេត្តក្រចេះ

- បានចុះដាំដុះសណ្តែកបាយក្រោយប្រមូលផលស្រូវវស្សានៅខេត្តតាកែវ និងខេត្តកំពត។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២២ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១០ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៩ក្រុមហ៊ុន សរុបចំនួន ៥៥សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈវគ្គទី២នៅខេត្តឧត្តរមានជ័យដែលមានអ្នកចូលរួមចំនួន១០២នាក់។

### ៨.៤ ការងារអនុវត្តច្បាប់

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តសៀមរាបចំនួន ៩ដេប៉ូ និងពិន័យ-អន្តរការណ៍ ១ករណី។

## ៩ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧៩៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣៤០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៣០ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១២៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ០៦១ច្បាប់

ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៦៣ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៦ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩៤៨នាក់ (ស្រី១ ៤៥៨នាក់) ស្មើនឹង២៤,៥១% រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៤នាក់ (ស្រី៨៣៥នាក់) ស្មើនឹង២៨,៦៥%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ០៣៤នាក់ (ស្រី៦២៣នាក់) ស្មើនឹង២០,៥៣%

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការដែលកំពុងបំពេញការងារនៅការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ចំនួន ៧៧៤នាក់ (ស្រី១៥០នាក់)

- បានចេញប្រកាសផ្ទេរមន្ត្រីរាជកាផ្ទៃក្នុងក្រសួងចំនួន ២នាក់ និងផ្ទេរមន្ត្រីរាជការក្រៅចូលក្នុងក្រសួងចំនួន ១នាក់

- បានបញ្ចូលមន្ត្រីក្របខ័ណ្ឌថ្មីចំនួន ១២០នាក់ (ស្រី៣៨នាក់) អង្គភាពថ្នាក់កណ្តាលចំនួន ៦៥នាក់ និងអង្គភាពថ្នាក់មន្ទីរកសិកម្មរាជធានី-ខេត្តចំនួន ៥៥នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ១នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៣៥៩នាក់ (ស្រី៦៦នាក់) ក្នុងនោះៈ
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៣៤៦នាក់ (ស្រី៦១នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ១៣នាក់ (ស្រី៥នាក់)។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានធ្វើលិខិតទៅរដ្ឋបាលព្រៃឈើសុំការអនុញ្ញាតចុះហត្ថលេខាលើឯកសារកិច្ចព្រមព្រៀងគម្រោងស្តីពី Establishment of High Value Tree Species Breeding Center in Cambodia សំណើសុំគោលការណ៍ ចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងអង្គការ GERES

- បានចុះតាមដាន និងវាយតម្លៃ (M&E) អង្គការ SNV នៅខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ និងអង្គការ Muslim Aid នៅខេត្តកំពង់ឆ្នាំង

- បានធ្វើលិខិតទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសុំសម្រួលឈ្មោះគម្រោង The Project for Capacity Building for Pesticide Residue Analysis in Agriculture Produce ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលជប៉ុន

- បានធ្វើលិខិតទៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ២ច្បាប់ គឺសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ដើម្បីដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំស្តីពី Seventh Word Ocean Summit នៅប្រទេសជប៉ុន សុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ដើម្បីដឹកនាំគណៈប្រតិភូចូលរួមទស្សនកិច្ចនៅក្រុមហ៊ុន Coconut Group Co., Ltd ប្រទេសចិន។

## ១២ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលគិតត្រឹមថ្ងៃទី១៥ ខែមករា នេះនៅមិនទាន់មានតួលេខនៅឡើយ
- អង្គភាពប្រមូលចំណូលទាំង៦នៅមិនទាន់បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៥ ៣៧២,៧២លានរៀល
- បានបញ្ចូលអាណត្តិ (AP) ក្នុងប្រព័ន្ធចំនួន៣ ប្រតិបត្តិការស្មើនឹងទឹកប្រាក់ចំនួន ៥ ៣៧២,៧២លានរៀល
- បានសម្របសម្រួលជាមួយក្រុមការងារFMIS/MEF ចុះមកក្រសួងMAFF/DAF ចំនួន ៣លើក
- បានរៀបចំធ្វើលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន ៦ក្រុមហ៊ុន
- បានរៀបចំធ្វើលិខិតសំណើបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន ៨ក្រុមហ៊ុន
- បានចូលរួមប្រជុំពិនិត្យវាយតម្លៃទីតាំងដីចំនួន ១កន្លែង ស្នើសុំកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលព្រៃឈើ

- បានចុះពិនិត្យវាយតម្លៃបញ្ចប់សុពលភាពស្ដីពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពឃ្លាំងដាក់គ្រឿងរថយន្ត ផ្ទះសំណាញ់ Nethouse លានហាលស្រូវ អាងស្តុកទឹកអាកាស អាងស្តុកទឹកបឋមនៅតាមមណ្ឌលអភិវឌ្ឍន៍កសិកម្ម និងស្ថានីយពិសោធន៍កសិកម្មចំនួន ៨កន្លែងរបស់អគ្គនាយកដ្ឋានកសិកម្ម ខេត្តកណ្តាល តាកែវ ស្វាយរៀង និងខេត្តឧត្តរមានជ័យ

- បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វរបស់ Livestock Sub-sector Component ក្រោមជំនួយហិរញ្ញប្បទានឥតសំណងសហភាពអឺរ៉ុប និងគម្រោង FAO ស្តីពីគំនិតផ្តួចផ្តើមគ្រប់គ្រងសុខភាពសត្វ-បរិស្ថានអនុតំបន់សម្រាប់ផលិតកម្មសត្វតាមគ្រួសារ (EAHIM) និងត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ព្រះសីហនុ កោះកុង កំពង់ចាម ក្រចេះ និងខេត្តស្ទឹងត្រែង

- បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វរបស់ Fisheies Sub-sector Component ក្រោមជំនួយហិរញ្ញប្បទានឥតសំណងសហភាពអឺរ៉ុបដែលបានបញ្ចប់ និងត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ សៀមរាប ព្រះវិហារ ត្បូងឃ្មុំ មណ្ឌលគិរី និងខេត្តរតនគិរី។

## ១៣ ផ្នែកអគ្គាធិការដ្ឋាន

- បានចុះធ្វើអធិការកិច្ចលើការដឹកនាំ និងគ្រប់គ្រងរបស់វិទ្យាស្ថានស្រាវជ្រាវកម្ពុជា

- បានទទួលរបាយការណ៍លើករណីភាពមិនប្រក្រតីក្នុងការអនុវត្តការងាររបស់ការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ដោយអញ្ជើញលោកប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាលមកធ្វើការបំភ្លឺ និងធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ

- បានអញ្ជើញលោក លោកស្រីប្រធានការិយាល័យទាំង១០ចំណុះឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺមកបំភ្លឺពាក់ព័ន្ធការងារដឹកនាំ និងគ្រប់គ្រងរបស់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ និងធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ

- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ១៤លើក។

## ១៤ ផ្នែកសវនកម្មផ្ទៃក្នុង

- បានធ្វើការបញ្ជូនតារាងសម្រង់ផែនការចំណាយតាមនីតិវិធីលទ្ធកម្មប្រចាំឆ្នាំ២០២០

- បានធ្វើការចាត់មន្ត្រីបង្គោលចំនួន ១នាក់សម្រាប់ទំនាក់ទំនងផ្តល់ឯកសារនានាសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តី

- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពចំនួន ៤អង្គភាព គឺៈ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ក្រចេះ ឧត្តរមានជ័យ និងនៅលើគម្រោងកម្មវិធីផលិតកម្មស្បៀង

- បន្តខិតខំបំពេញភារកិច្ចដែលមានចែងក្នុងអនុក្រឹតលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

- គ្រោងចុះធ្វើសវនកម្មផ្ទៃក្នុង តាមដានការកែលម្អរបស់សវនដ្ឋានតាមផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៩ និងតាមការចង្អុលបង្ហាញផ្ទាល់របស់ឯកឧត្តមរដ្ឋមន្ត្រី។

## ១៥ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី)

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្តុះបណ្តាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន០២ ដូចជាៈ ខេត្តសៀមរាប និងខេត្តកំពង់ធំ

- បានចុះប្រមូលទីតាំងដំណាំស្រូវប្រាំងក្នុងខេត្តតាកែវ និងខេត្តព្រៃវែង ដើម្បីរៀបចំផែនទីដំណាំកសិកម្មសម្រាប់បញ្ចូលក្នុងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើប្រាស់គេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន០២ គឺៈ ខេត្តក្រចេះ និងខេត្តសៀមរាប។

## ១៦ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បាននិងកំពុងបន្តសហការអនុវត្តគម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

- បានបើកសិក្ខាសាលាស្តីពីការងារផ្សព្វផ្សាយកសិកម្មប្រចាំឆ្នាំ និងការអង្កេតអ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មពាក់កណ្តាលកម្មវិធីមានអ្នកចូលរួមចំនួន១១៥នាក់

- គ្រោងចុះផលិតវេទិកាស្វែងយល់ពីកសិកម្មស្តីពីការចូលរួមចំណែកលើវិស័យកសិកម្មចំពោះសេដ្ឋកិច្ចជាតិ

- គ្រោងចុះថតនាទីចុះស្រែជាមួយកសិករនៅខេត្តពោធិ៍សាត់ស្តីពីបច្ចេកទេសចិញ្ចឹមមាន់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការដាំដំណាំបន្លែបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- បានរៀបចំបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកសិកម្មស្តីពីបទពិសោធន៍អំពីការចិញ្ចឹមត្រី និងផលិតពូជត្រីទីឡាព្យ៉ាក្រហម និងបទពិសោធន៍នៃការធ្វើទឹកម្ទេស

- គេហទំព័រមានអ្នកទាញឯកសារផ្សេងៗចំនួន ៥៦ ៥៥៣ដង។

## ១៧ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក

- បានចុះណែនាំស្ទង់ទិន្នផលស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

- បានរៀបចំសិក្ខាសាលាស្តីពីបច្ចេកវិទ្យាព័ត៌មានលើការប្រមូល និងប្រើប្រាស់ទិន្នន័យសម្រាប់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងកសិកម្ម

- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តចំនួន ២៥

- បានចូលរួមចុះពិនិត្យ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសំណើសុំជួយដោះស្រាយបញ្ហាដីចំនួន ៦៧០ហ.ត ដែលឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តស្វាយរៀងបានប្រគល់ឱ្យក្រុមហ៊ុន អិន ខេ វេនឈរ (ខេមបូឌា) លីមីធីត។

## ១៨ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៨.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- មហាវិទ្យាល័យទាំងអស់បាននឹងកំពុងប្រឹងប្រែងបង្រៀនបញ្ចប់កម្មវិធីសិក្សារបស់ខ្លួននឹងចាប់ផ្តើមប្រឡងឆមាសទី១ នៅដើមខែកុម្ភៈខាងមុខនេះ ព្រមទាំងបានដឹកនាំនិស្សិតចុះទស្សនកិច្ចសិក្សានៅតាមបណ្តាខេត្ត

- បានដំឡើងម៉ាស៊ីនដុតកាកសំណល់វេជ្ជសាស្ត្រ (Incinerator) សម្រាប់ប្រើប្រាស់នៅក្នុងមន្ទីរពេទ្យសត្វនៃមហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ

- បានទទួលត្រាក់ទ័រ Oggun និងម៉ាស៊ីនដាំបន្លែបំពាក់ក្រោយត្រាក់ទ័រចំនួន ១គ្រឿង ពីUSAID សហរដ្ឋអាមេរិក សម្រាប់ពង្រឹងការសិក្សានិងស្រាវជ្រាវរបស់មន្ត្រីសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាពិសេសមហាវិទ្យាល័យវិស្វកម្មកសិកម្ម

- បានប្រជុំពិភាក្សាជាមួយគណៈប្រតិភូសាកលវិទ្យាល័យ Poznan University of Life Sciences នៃប្រទេសប៉ូឡូញអំពីកិច្ចសហប្រតិបត្តិការលើការងារអប់រំបណ្តុះបណ្តាល ស្រាវជ្រាវ ការផ្លាស់ប្តូរនិស្សិត និងការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាជាន់ខ្ពស់ដល់និស្សិតកម្ពុជា

- បានសហការជាមួយមជ្ឈមណ្ឌល CE SAIN រៀបចំសិក្ខាសាលាស្តីពីគ្រឿងយន្តកសិកម្មតាមបែបប្រព័ន្ធចំហ (Open System)សម្រាប់កម្ពុជា

- បានរៀបចំសិក្ខាសាលាអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មដែលពិភាក្សាផ្តោតលើចក្ខុវិស័យ សូចនាករលទ្ធផលសម្រេច ស្តង់ដារវាស់វែងសូចនាករលទ្ធផល និងគោលការណ៍តាមដានវាយតម្លៃក្របខណ្ឌលទ្ធផលកម្រិតសាកលវិទ្យាល័យ និងមហាវិទ្យាល័យ។

### ១៨.២ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៩៣៧នាក់ (ស្រី៣៨៩នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានរៀបចំពិធីការពារគម្រោងស្នើសុំប្រធានបទរបស់និស្សិតដើម្បីសរសេរសារណាបញ្ចប់ការសិក្សា

- បាននិងកំពុងពិនិត្យ និងកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ បរិញ្ញា និងបរិញ្ញារង បន្ទាប់ពីទទួលកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់គ្រប់ជំនាញ

- បាននិងកំពុងដំណើរការសាងសង់អគារសម្រាប់ចិញ្ចឹមត្រីឆ្តក ត្រីដំរី

- បាននិងកំពុងដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ។

### ១៨.៣ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៧១៩នាក់ (ស្រី២៨៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានរៀបចំសាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅខេត្តកំពង់ចាម

- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកលើអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ជលផលរបស់សាលា

- បានពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បានបន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ជង្កូវនាងព្រៃ

- បានសហការជាមួយលោកសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យជាតិកាង វ៉ុន ចុះធ្វើការស្រាវជ្រាវប្រភេទរុក្ខជាតិនៅកម្ពុជា និងចម្រាញ់ប្រេងរុក្ខជាតិចេញពីម្រេចបង្កើតបានជាទឹកអប់

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ប៉េងប៉ោះ ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសសម្រេចបានចំនួន ៥៧៤ ៥៣៣ហ.ត ស្មើនឹង១២៥,០១% នៃផែនការ ៤៥៩ ៥៩៤ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការដាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

IV- **ទិសដៅអនុវត្តបន្ត**

**១ ផ្នែកដាំដុះ**

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល**

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- បន្តអនុវត្តការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត។

**៣ ផ្នែកព្រៃឈើ**

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តប្រារព្ធពិធីរុក្ខទិវាជាតិ ០៩កក្កដា និងបន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគី និងពហុភាគីសម្រាប់ការបណ្តុះ-បណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេច

លេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ សុក្រ ១៣កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**